# ចែករំលែកចំណេះដឹងនៃបទពិសោធន៍
# SHARE EXPERIENCE KNOWLEDGE

**ចំណេះដឹងទូទៅ**
**(General Knowledge)**

ប្រធានបទសម្រាប់ចែករំលែក (Subject to be shared) : បួនចំនុចសំខាន់ៗនៃគុណភាពនៃការគិត

កាលបរិច្ឆេទនៃការចែករំលែក (Date of this sharing) : ០៩ ឧសភា ២០១២

ចែករំលែកចំណេះដឹងដោយ (Knowledge shared by) : លោក សៀង ប៊ូហឿង

## ១. សេចក្តីផ្តើម (Introduction)




ក្នុងសង្គមរស់នៅបច្ចុប្បន្នរបស់យើងទាំងអស់គ្នា គឺមិនអាចជៀសផុតពីការគិតបានទេ។ គុណភាពនៃការគិត សំដៅទៅលើការគិតត្រូវ ការនិយាយត្រូវ ការធ្វើត្រូវ និងការដឹងថាធ្វើត្រូវ។ ដូច្នេះវាមិនមែនជាការងាយទេក្នុងការទទួលបានគុណភាពនៃការគិត ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ យើងសង្កេតឃើញថាមនុស្សភាគច្រើនចង់ទទួលបានគុណភាពនៃការគិតរបស់ពួកគេ។ ដូច្នេះដើម្បីទទួលបានគុណភាពនៃការគិត ជាបឋមអ្នកត្រូវយល់ដឹងអំពីនិយមន័យ របៀបក្នុងការប្រតិបត្តិ និងវិធីក្នុងការពង្រឹងសមត្ថភាពនៃការគិត ដើម្បីទទួលបានគុណភាពនៃការគិត។

**២. ការយល់ដឹង (Knowledge)**

ការពន្យល់របស់ខ្ញុំបាទអំពីបួនចំនុចសំខាន់ៗនៃគុណភាពនៃការគិត មានដូចខាងក្រោម :

**ក.ការគិតត្រូវ**

មានន័យថា អ្វីដែលយើងគិតនោះ វាសមស្របទៅនឹងស្ថានការជាក់ស្តែង ហើយស្របនឹងគោលបំណង ឬគោលដៅនៃការគិតរបស់យើង។

**ខ.ការនិយាយត្រូវ**

មានន័យថា រាល់សម្តីដែលយើងនិយាយចេញមក អោយវាត្រូវទៅនឹងអ្វីដែលយើងបានគិតក្នុងចិត្ត។ បើគិតចង់លួងលោមគេ សម្តីនិយាយចេញមកត្រូវទន់ភ្លន់ និងលើកទឹកចិត្តគេ បើចង់ស្តីអោយគេ ត្រូវសម្តីយ៉ាងម៉េចធ្វើអោយគេដឹងថាកំពុងតែស្តីអោយគេ ហើយបើចង់ធ្វើការណែនាំគេ អោយចំណែនាំ អញ្ចឹងទើបហៅថាការនិយាយត្រូវ គឺត្រូវទៅនឹងការគិតរបស់ខ្លួនដែលបានគិតទុកជាមុន មិនមែនត្រូវនឹងការគិតរបស់អ្នកដទៃទេ។

**គ.ការធ្វើត្រូវ**

មានន័យថា ទង្វើ ឬសកម្មភាពដែលសំដែងចេញមកក្រៅ គឺវាត្រូវទៅនឹងការដែលបានគិត និងបាននិយាយរួចមកហើយ។ បើគិតថាជួយគេ នឹងនិយាយថាជួយគេ ហើយធ្វើសកម្មភាពជួយគេពិតប្រាកដមែន ហ្នឹងទើបគេហៅថាការធ្វើត្រូវ គឺត្រូវទៅនឹងការគិត និងការនិយាយរបស់ខ្លួន។

**ឃ.ការដឹងថាធ្វើត្រូវ**

មានន័យថា លទ្ធផល ឬការឆ្លើយតបដែលស្តែងចេញពីទង្វើដែលបានធ្វើ វាពិតជាត្រូវនឹងការគិត ការនិយាយ និងការធ្វើរបស់ខ្លួន។ ជំនាញក្នុងការប្រមូល និងទទួលបាននូវលទ្ធផល ឬការឆ្លើយតប វាពិតជាមានសារៈសំខាន់ណាស់នៅត្រង់ចំនុចនេះ ហើយជំនាញនេះទាមទារអោយយើងមានចំណេះដឹងនៃបទពិសោធន៍ទូលំទូលាយ។

**៣. ការផ្តល់អនុសាសន៍ (Recommendation)**

ចំពោះការគិតត្រូវ ការនិយាយត្រូវ ការធ្វើត្រូវ និងការដឹងថាធ្វើត្រូវ នៅក្នុងន័យនេះគឺមានតែខ្លួនឯងទេ ដែលដឹងច្បាស់ដែលទាំងនេះមានប្រភពចម្បងផ្តើមចេញពីគោលបំណង ឬគោលដៅរបស់ខ្លួន។ ដូច្នេះសរុបសេចក្តីមក ជារួមមានន័យថា:

-ការគិតត្រូវ : គឺការគិតដ៏ល្អប្រសើរស្របតាមស្ថានការជាក់ស្តែង ហើយត្រូវនឹងគោលបំណង ឬគោលដៅរបស់ខ្លួន។

-ការនិយាយត្រូវ : គឺជាសម្តីដែលត្រូវទៅនឹងការគិតរបស់ខ្លួន។

-ការធ្វើត្រូវ : គឺជាទង្វើដែលត្រូវទៅនឹងការគិត និងការនិយាយរបស់ខ្លួន។

-ការដឹងថាធ្វើត្រូវ : គឺជាលទ្ធផលដែលត្រូវទៅនឹងការគិត ការនិយាយ និងការធ្វើរបស់ខ្លួន។

ដូច្នេះអ្នករាល់គ្នាត្រូវមានការប្រុងប្រយ័ត្នកម្រិតខ្ពស់ចំពោះសម្ថភាពនៃការគិតត្រូវរបស់អ្នក។ ជូនកាលក្នុងករណីដែលអ្នកដឹងច្បាស់ថា សម្ថភាពនៃការគិតរបស់អ្នកនៅមានកម្រិត អ្នកក៏អាចពឹងអ្នកដែលមានសម្ថភាពនៃការគិតកម្រិតខ្ពស់ជាងជួយដល់អ្នក។ ការគិតត្រូវ គឺចេញពីសមត្ថភាពនៃការគិត ដោយត្រូវមាននូវលក្ខណៈពិសេសមួយចំនួនដូចខាងក្រោម :

-ការប្រមូល ឬទទួលបានព័ត៌មានគ្រប់គ្រាន់ជុំវិញបញ្ហាដែលត្រូវគិត

-ការវិភាគដើម្បីស្វែងរកការពិត

-ចំណេះដឹងនៃបទពិសោធន៍ដែលដូចគ្នា ឬប្រហាក់ប្រហែលនឹងបញ្ហាដែលត្រូវគិត

-ចំណេះដឹងនៃបទពិសោធន៍ដែលពាក់ព័ន្ធ

-ចំណេះដឹងនៃជំនាញដែលពាក់ព័ន្ធ

-ស្ថានការណ៍សមស្រប ឬអំណោយផលចំពោះការគិត ។